ក្រសួងអប់រំរដ្ឋ NSW

# ការវាយតម្លៃលើការចាប់ផ្ដើមចូលសាលាមត្តេយ្យបានល្អបំផុត

## ការណែនាំសម្រាប់ឪពុកម្ដាយ និងអ្នកថែទាំ

**ការវាយតម្លៃលើការចាប់ផ្ដើមចូលសាលាមត្តេយ្យបានល្អបំផុត គឺជាការវាយតម្លៃទូទាំងរដ្ឋ ដែលជួយគ្រូបង្រៀនកំណត់ជំនាញអក្ខរកម្ម និងការចេះរាប់លេខជាភាសាអង់គ្លេសរបស់សិស្សម្នាក់ៗ នៅពេលចាប់ផ្ដើមសាលាមត្តេយ្យ។**




កុមារចាប់ផ្ដើមចូលរៀនដោយមានជំនាញអក្ខរកម្ម និងការចេះរាប់លេខ ចំណេះដឹង ហើយនិងការយល់ដឹងដែលបានបង្កើតឡើងពីការទំនាក់ទំនងជាមួយពិភពលោក និងមនុស្សជុំវិញពួកគេជាច្រើននៅគ្រាដំបូង។ ការវាយតម្លៃលើការចាប់ផ្ដើមចូលសាលាមត្តេយ្យបានល្អបំផុត រួមមានផ្នែកអក្ខរកម្ម និងការចេះរាប់លេខ ហើយផ្ដល់ឱ្យគ្រូបង្រៀននូវព័ត៌មានអំពីចំណុចខ្លាំង និងតម្រូវការផ្ទាល់ខ្លួនរបស់សិស្ស។

ការវាយតម្លៃនេះគាំទ្រគ្រូបង្រៀនដើម្បីបង្កើតកម្មវិធីបង្រៀន និងការរៀនសូត្រដែលផ្អែកលើអ្វីដែលសិស្សដឹង។ គ្រូបង្រៀនអង្គុយជាមួយសិស្សម្នាក់ៗ ដោយផ្ដោតលើអ្វីដែលពួកគេអាចធ្វើបាន។ កូនរបស់អ្នកមិនចាំបាច់ប្រុងប្រៀប ឬសិក្សាសម្រាប់ការវាយតម្លៃនេះទេ។ ដោយព្រោះតែកុមាររៀនក្នុងល្បឿនផ្សេងៗគ្នា ឪពុកម្ដាយមិនចាំបាច់ព្រួយបារម្ភទេ ប្រសិនបើកូនរបស់អ្នកមិនអាចឆ្លើយគ្រប់ទាំងសំណួរ។

បន្ទាប់ពីការវាយតម្លៃភ្លាមនោះ គ្រូបង្រៀននឹងផ្ដល់ឱ្យអ្នកនូវព័ត៌មានអំពីជំនាញ ចំណេះដឹង និងការយល់ដឹងដែលកូនរបស់អ្នកបានបង្ហាញក្នុងអំឡុងពេលវាយតម្លៃ។

ការវាយតម្លៃលើការចាប់ផ្ដើមចូលសាលាមត្តេយ្យបានល្អបំផុត គឺរាប់បញ្ចូលសិស្សទាំងអស់។ ប្រសិនបើភាសាអង់គ្លេសមិនមែនជាភាសាកំណើតរបស់អ្នកទេ ឬកូនរបស់អ្នកទាមទារការកែតម្រូវនានា សូមទាក់ទងសាលារៀនរបស់អ្នកសម្រាប់ព័ត៌មានបន្ថែមអំពីរបៀបគាំទ្រកូនរបស់អ្នក។

### ការវាយតម្លៃអក្ខរកម្ម

កិច្ចការអក្ខរកម្មត្រូវបានរៀបចំឡើងដើម្បីកំណត់ថាតើសិស្សអាចសរសេរឈ្មោះរបស់ពួកគេ ស្គាល់សំឡេង អក្សរ និងពាក្យដែលធ្លាប់ស្គាល់ ហើយរម្លឹកឡើងវិញនូវព័ត៌មានលម្អិត អំពីសៀវភៅខ្លីដែលបានអានដល់ពួកឬអត់។

ក្នុងអំឡុងពេលវាយតម្លៃអក្ខរកម្ម គ្រូបង្រៀននឹងសួរសំណួរនានាដូចជា៖

- 'ស្ដាប់ពាក្យទាំងនេះ៖ map, tap។ តើអ្នកអាចគិតឃើញពាក្យមួយទៀតដែលចួនគ្នាទេ? '
- (បន្ទាប់ពីអានសៀវភៅខ្លីមួយ) 'តើអ្នកអាចប្រាប់ខ្ញុំបានទេ អំពីសាច់រឿងដែលខ្ញុំទើបតែអានដល់អ្នក?'

សំណួរទាំងនេះជួយគ្រូបង្រៀនកំណត់ ថាតើកូនរបស់អ្នកអាចស្គាល់ពាក្យនានាដែលមានសំឡេងដូចគ្នា និងរំលឹកឡើងវិញនូវព័ត៌មានចេញពីសៀវភៅខ្លីដែលបានអានដល់ពួកគេឬអត់។ ទាំងនេះគឺជាជំនាញអក្ខរកម្មដ៏សំខាន់ដែលកុមារនឹងអភិវឌ្ឍក្នុងឆ្នាំដំបូងរបស់ពួកគេនៅសាលារៀន។

### ការវាយតម្លៃការចេះរាប់លេខ

កិច្ចការចេះរាប់លេខទាក់ទិននឹងរបៀបគិតលេខគ្រាដំបូង ហើយត្រូវបានរៀបចំឡើងដើម្បីកំណត់ ថាតើសិស្សអាចរាប់លេខបានល្អយ៉ាងណាដែរ តើលេខមួយណាដែលពួកគេអាចសម្គាល់ដឹង ថាតើពួកគេអាចរាប់វត្ថុ បូក ឬដកលេខតូចៗ និងសម្គាល់ដឹងលំនាំដដែលៗឬអត់។

ក្នុងអំឡុងពេលវាយតម្លៃការចេះរាប់លេខ គ្រូបង្រៀននឹងសួរសំណួរនានាដូចជា៖

- 'ចាប់ផ្ដើមរាប់ពីមួយទៅ ហើយខ្ញុំនឹងប្រាប់អ្នកថាពេលណាត្រូវឈប់'
- 'តើអ្នកអាចប្រាប់ខ្ញុំបានទេថានេះជាលេខអ្វី?' (5)

សំណួរទាំងនេះនឹងជួយគ្រូបង្រៀនកំណត់ថាតើកូនរបស់អ្នកអាចសម្គាល់ដឹងលេខ និងរាប់ពីមួយបានឬអត់។ ទាំងនេះគឺជាជំនាញការរាប់លេខដ៏សំខាន់ ដែលកុមារនឹងអភិវឌ្ឍក្នុងឆ្នាំដំបូងរបស់ពួកគេនៅសាលារៀន។

**សម្រាប់ព័ត៌មានបន្ថែមអំពី ការវាយតម្លៃលើការចាប់ផ្ដើមចូលសាលាមត្តេយ្យបានល្អបំផុត សូមទាក់ទងសាលារៀនរបស់កូនអ្នក។**

**ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ សូមទាក់ទងសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ តាមលេខ 131 450។ ពួកគេអាចរៀបចំឱ្យមានអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក ដើម្បីជួយដល់ការសន្ទនាជាមួយសាលារៀន។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។**